ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# អ្នកជំងឺជាជនជាតិចិននៅខេត្តព្រះសីហនុ ត្រូវបានអនុញ្ញាតឲ្យចាកចេញពីមន្ទីរពេទ្យបន្ទាប់ពីលទ្ធផលតេស្តអវិជ្ជមានវីរុសកូរ៉ូណាថ្មី (2019-nCoV) លើកទី៣

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា អ្នកជំងឺរលាកសួតដោយវីរុសកូរ៉ូណាថ្មី (2019-nCoV) ដែលជាជនជាតិចិននោះ ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យនៅថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ នេះហើយ ក្រោយពីការធ្វើតេស្តលើកទី៣ បង្ហាញនូវលទ្ធផលអវិជ្ជមានវីរុសកូរ៉ូណាថ្មី (2019-nCoV) ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងមានសុខភាពល្អប្រសើរ រីឯក្រុមគ្រួសារជនជាតិចិនរូបនេះ ៣នាក់ទៀត ក៏ត្រូវបានរួចផុតពីការសង្កេតសុខភាព ហើយអាចជួបជុំគ្នាវិញជាធម្មតាហើយដែរ។

បុរសជាជនជាតិចិនខាងលើនេះ ត្រូវបានរកឃើញតាមរយៈការធ្វើតេស្តវត្តមានវិជ្ជមានវីរុសកូរ៉ូណាប្រភេទថ្មី (2019-nCoV) នៅខេត្តព្រះសីហនុ នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ បន្ទាប់មកត្រូវបានដាក់ឲ្យនៅដាច់ដោយឡែក នៅក្នុងមន្ទីរពេទ្យខេត្តព្រះសីហនុ ដើម្បីផ្តល់ការព្យាបាល និងពិនិត្យតាមដានស្ថានភាពជំងឺរបស់បុរសរូបនេះ ដោយមានការយកចិត្តទុកដាក់ជាទីបំផុតពីសំណាក់ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យខេត្តនេះ។

ក្រោយពីលទ្ធផលតេស្តអវិជ្ជមានវីរុសកូរ៉ូណាថ្មីលើកទី២ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០ ក្រសួងសុខាភិបាលដោយមានការពិភាក្សាជាមួយអង្គការសុខភាពពិភពលោក បានសម្រេចមិនទាន់អនុញ្ញាតឲ្យបុរសរូបនេះចេញពីមន្ទីរពេទ្យ ដោយត្រូវបន្តតាមដានសុខភាពគាត់និងរង់ចាំលទ្ធផលតេស្តលើកទី៣។ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ ក្រោយពីទទួលបានការបញ្ជាក់ពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានូវលទ្ធផលតេស្តអវិជ្ជមានវីរុសកូរ៉ូណាថ្មីលើកទី៣ ក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យខេត្តព្រះសីហនុ បានត្រួតពិនិត្យសារឡើងវិញនូវស្ថានភាពសុខភាពបុរសជនជាតិចិនខាងលើឃើញថាគាត់មានសុខភាពល្អប្រសើរ ទើបនៅព្រឹកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រសួងសុខាភិបាលបានសម្រេចថាអ្នកជំងឺបានជាសះស្បើយ និងត្រូវបានអនុញ្ញាតឲ្យបុរសជនជាតិចិនរូបនេះ ចាកចេញពីមន្ទីរពេទ្យខេត្តព្រះសីហនុនៅព្រឹកថ្ងៃដដែលនេះតែម្តង ដោយមានវត្តមានឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម សា យ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន អមដំណើរដោយលោកជំទាវវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល ព្រមទាំងមន្ត្រីជាន់ខ្ពស់នៃក្រសួងសុខាភិបាល តំណាងឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ លោកស្រីឱសថការី លឹម សាមាន ប្រធានមន្ទីរសុខាភិបាលខេត្តព្រះសីហនុ និងមន្ត្រីជាច្រើននាក់ រួមទាំងក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យខេត្តព្រះសីហនុ លោកស្រី លី អៃឡាន (Dr. Li Ailan, WHO Representative in Cambodia) តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា និងតំណាងស្ថានទូតចិននៅកម្ពុជា ក៏មានវត្តមាននៅទីនោះផងដែរ។

សូមគូសបញ្ជាក់ថា ដោយមានការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ជាពិសេសការណែនាំចង្អុលបង្ហាញប្រកបដោយទេពកោសល្យខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាលបានខិតខំត្រៀមត្រៀមត្រាប់អនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការឆ្លើយតបបន្ទាន់អប់រំសុខភាពជូនដល់បងប្អូនប្រជាពលរដ្ឋ និងស្រាវជ្រាវករណីសង្ស័យយ៉ាងសកម្មបំផុត រហូតមកដល់ពេលនេះ ពុំទាន់មានរកឃើញករណីផ្ទុកមានវីរុសកូរ៉ូណាថ្មីនៅលើប្រជាជនកម្ពុជា ឬជនបរទេសណាម្នាក់ទៀតនោះឡើយ ក្រៅតែពីមានរកឃើញតែមួយករណីគត់ដែលជាជនជាតិចិន កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥ ហើយដែលបានឲ្យចាកចេញពីមន្ទីរពេទ្យនាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ នេះរួចហើយដែរ។

ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានសំដែងនូវមនោសញ្ចេតនារីករាយ និងសាទរចំពោះបុរសជនជាតិចិនដែលបានជាចេញពីមន្ទីរពេទ្យ និងក្រុមគ្រួសារទាំងអស់ ដែលបានរួចផុតពីការសង្កេតសុខភាព ហើយបានជូនពរដល់ពួកគាត់ឲ្យមានសុខភាពល្អ វិលត្រឡប់ទៅជួបជុំបងប្អូនក្រុមគ្រួសារនៅលំនៅដ្ឋានរបស់ខ្លួនប្រកបដោយសុខសុវត្ថិភាព។ លើសពីនេះ ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីបានផ្តាំផ្ញើ និងផ្តល់ការណែនាំថា ទោះជាជនជាតិចិនរូបនេះមិនមានផ្ទុកមានវីរុសកូរ៉ូណាថ្មីពលើកក៏ដោយ បុរសជនជាតិចិន និងក្រុមគ្រួសារទាំងអស់របស់គាត់ ត្រូវតែបន្តអនុវត្តវិធានការការពារសុខភាពផ្ទាល់ខ្លួនយ៉ាងខ្ជាប់ខ្ជួនជាទីបំផុត ជាពិសេសត្រូវមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការអាចមានចម្លងវីរុសកូរ៉ូណាថ្មីនេះជាលើកទីពីរ នៅពេលដែលការរាតត្បាតដោយវីរុសថ្មីនេះ នៅមានបន្តនៅឡើយ ដោយអនុវត្តនូវវិធានការដូចខាងក្រោម។

លើសពីនេះ ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល បានសំដែងនូវការកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងសុខាភិបាល អាជ្ញាធរខេត្តព្រះសីហនុ ជាពិសេសចំពោះថ្នាក់ដឹកនាំ និងក្រុមគ្រូពេទ្យនៃមន្ទីរសុខាភិបាលខេត្ត និងមន្ទីរពេទ្យខេត្តព្រះសីហនុទាំងអស់ ដែលបានយកចិត្តទុកដាក់អនុវត្តវិធានឆ្លើយតបបន្ទាន់ បានទាន់ពេលវេលា និងបានខិតខំពិនិត្យ ព្រមទាំងព្យាបាលជំងឺដល់បុរសជនជាតិចិនខាងលើ រហូតបានជាសះស្បើយចេញពីមន្ទីរពេទ្យ។

ដើម្បីចូលរួមការពារទប់ស្កាត់ការចម្លងវីរុសកូរ៉ូណាប្រភេទថ្មីនេះនៅប្រទេសកម្ពុជា ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមក្រើនរំលឹកហើយរំលឹកទៀត និងបន្តអំពាវនាវដល់បងប្អូនជនរួមជាតិទាំងអស់ រួមទាំងអ្នកធ្វើដំណើរដែលមានគម្រោងទៅកាន់ ឬត្រលប់មកពីប្រទេសក្រៅ ជាពិសេសខេត្តដែលកំពុងផ្ទុះនូវជំងឺនេះនៅប្រទេសចិន ត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត «ប្រសិនបើលោកអ្នក មានរោគសញ្ញាដូចជា គ្រុនក្តៅ ក្អក និងពិបាកដកដង្ហើម ទាំងមុន ឬក្នុងអំឡុងពេលធ្វើដំណើរ ឬបន្ទាប់ពីការវិលត្រលប់មកពីកន្លែងដែលបាននិងកំពុងរាតត្បាតនៅប្រទេសចិន សូមទៅពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិត នៅតាមគ្រឹះស្ថានសុខាភិបាលសាធារណៈដែលនៅជិតបំផុតភ្លាម និងប្រាប់ព័ត៌មានដល់គ្រូពេទ្យ ពីប្រវត្តិនៃការធ្វើដំណើរ និងរោគសញ្ញារបស់លោកអ្នក»។

ជាមួយគ្នានោះដែរ សូមបងប្អូនប្រជាពលរដ្ឋអនុវត្តនូវវិធានការសាមញ្ញៗ មានដូចខាងក្រោមនេះ៖

- ជៀសវាងប៉ះពាល់ជិតស្និទ្ធជាមួយអ្នកមានជំងឺផ្លូវដង្ហើមស្រួច ដូចជា គ្រុនក្តៅ ក្អក និងកណ្តាស់ ឬផ្តាសាយ។
- ត្រូវលាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ឬអាល់កុលហ្សែល បន្ទាប់ពីការប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំងឺ ឬបរិស្ថានជុំវិញគាត់ ឬ នៅពេលឃើញដៃកខ្វក់ ឬប្រឡាក់។
- ជៀសវាងប៉ះពាល់ជិតស្និទ្ធ ឬទៅទីផ្សារលក់គ្រឿងសមុទ្រហូណាន ឬទីផ្សារ ឬកសិដ្ឋានដែលគេចិញ្ចឹមសត្វរស់ ឬសត្វព្រៃ ឬកន្លែងដែលគេដឹងថាមានវីរុសកំពុងរាតត្បាត។ ចាំបាច់ត្រូវលាងដៃឲ្យបានទៀងទាត់ និងញឹកញាប់មុនពេល និងក្រោយពីការប៉ះពាល់សត្វ ឬវត្ថុផ្សេងៗដែលអាចជាប្រភពមេរោគ។

• ប្រកាន់ខ្ជាប់នូវការអនុវត្តអនាម័យស្អាត និងសុវត្ថិភាពម្ហូបអាហារឲ្យបានត្រឹមត្រូវល្អ ពិសារអាហារដែលចម្អិនឆ្អិនល្អ ជាពិសេសសាច់ និងស៊ុត។

• ត្រូវខ្ទប់មាត់ និងច្រមុះនៅពេលក្អក ឬកណ្តាស់ ដោយកន្សែង ក្រមាំ ក្រដាសជូតមាត់ ឬដោយផ្នត់បត់កែងដៃ។

• ត្រូវប្រកាន់យកនូវអនាម័យដៃស្អាត និងអនាម័យផ្លូវដង្ហើម ( ខ្ទប់មាត់ និងច្រមុះនៅពេលក្អក ឬកណ្តាស់ លាងដៃបន្ទាប់ពីមានប៉ះជាមួយទឹករំអិលពីផ្លូវដកដង្ហើម និងរក្សាចម្ងាយច្រើនជាង១ម៉ែត្រ ជាមួយបុគ្គលដែលមានរោគសញ្ញាផ្លូវដង្ហើមស្រួចស្រាវ )។

• ជៀសវាងការប៉ះពាល់ភ្នែក ច្រមុះ និងមាត់ បន្ទាប់ពីប៉ះពាល់សត្វ និងផលិតផលសត្វ សត្វឈ្មោល សាច់ខូចគុណភាព កាកសំណល់សត្វ ឬទឹកសរីរៈសត្វក្នុងផ្សារ។

• ជៀសវាងការខាកស្តោះនៅទីសាធារណៈ

• ប្រើប្រាស់ ជ្រុញ និងកាំបិត ផ្សេងគ្នា សំរាប់អាហារឆៅ និងអាហារឆ្អិន និងលាងដៃ នៅចន្លោះពេលចាប់កាន់អាហារឆៅ និងអាហារឆ្អិន។

• ចំពោះអ្នកលក់នៅទីផ្សារសត្វរស់ ត្រូវលាងសំអាតឧបករណ៍ និងទីកន្លែងលក់ដូរយ៉ាងតិច ១ដងក្នុងមួយថ្ងៃ ដើម្បីសំលាប់មេរោគ។

• បុគ្គលិកសុខាភិបាលដែលផ្តល់ការថែទាំអ្នកជំងឺត្រូវប្រកាន់ខ្ជាប់នូវវិធានការបង្ការការចម្លងរោគក្នុងគ្រឹះស្ថានសុខាភិបាលឲ្យបានហ្មត់ចត់ និងត្រឹមត្រូវដើម្បីជៀសវាងការឆ្លងជំងឺនេះមកបុគ្គលខ្លួនឯង។

• ប្រសិនបើសង្ស័យថាឆ្លងជំងឺរលាកសួតដោយវីរុសកូរ៉ូណាប្រភេទថ្មី ដោយមានគ្រុនក្តៅ ៣៨អង្សាសេ និងមានរោគសញ្ញាមួយយ៉ាងតិចក្នុងចំណោម ក្អក ហៀរសំបោរ ឈឺបំពង់ក ដង្ហើមខ្លី និងពិបាកដកដង្ហើម និងមានប្រវត្តិធ្វើដំណើរមកពីប្រទេសចិន ដោយបានប៉ះពាល់ជាមួយអ្នកជំងឺផ្លូវដង្ហើម ប៉ះពាល់ជាមួយសត្វឈ្មោល ក្នុងអំឡុង១៤ថ្ងៃ មុនចេញរោគសញ្ញា ឬដោយបានប៉ះពាល់ជាមួយអ្នកស្លាប់ដោយសារជំងឺផ្លូវដង្ហើមស្រួចស្រាវមិនដឹងអំពីអត្តសញ្ញាណ (ប្រភេទមេរោគ) ច្បាស់លាស់ ត្រូវប្រញាប់រាយការណ៍ទៅលេខទូរស័ព្ទទាន់ហេតុការណ៍ 115 និងពិនិត្យព្យាបាលជំងឺឲ្យបានទាន់ពេលវេលានៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដូចជាមន្ទីរពេទ្យរដ្ឋដែលបានត្រៀមលក្ខណៈរួចជាស្រេចដើម្បីជួយពិនិត្យ និងព្យាបាលជូនដល់បងប្អូន។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជនអំពីការវិវត្តនៃបញ្ហាសុខភាពតាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh (ht t p://www.cdcmoh.gov.kh/) ដែលគេហទំព័រនេះមានសំភារៈអប់រំសុខភាព ដែលអាចទាញយកមកមើលបាន និងហ្វេសប៊ុកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល។

សំរាប់ព័ត៌មានបន្ថែមៈ សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ 115 ទោះគ្មានថវិកាក្នុងទូរស័ព្ទរបស់អ្នក ក៏អាចទូរស័ព្ទចូលបានដែរ ឬទំនាក់ទំនងៈ

| | | |
|---|---|---|
| ក្រសួងសុខាភិបាល | -លោកវេជ្ជបណ្ឌិត លី សុវ៉ាន់ | ៖ ០១២ ៨២៥ ៤២៤ |
| | -លោកវេជ្ជបណ្ឌិត យី សេងឌឿន | ៖ ០១២ ៤៨៨ ៩៨១ |
| | -លោកស្រីវេជ្ជបណ្ឌិត គេង ស្រី | ៖ ០១២ ៨៣៦ ៨៦៨ |

ថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០